
Kids of Destiny
Reaching the Next Generation
www.kidsofdestiny.org

# 4.04 ស្ដេចមួយអង្គផ្សេងទៀតត្រូវបានជ្រើសរើស

សាំយូអែលធ្លាប់ជាចៅក្រមម្នាក់ គ្រប់គ្រងលើជនជាតិអ៊ីស្រាអែលអស់ជាច្រើនឆ្នាំ។ បន្ទាប់មកប្រជាជនចង់បានស្ដេចមួយអង្គផ្សេងទៀត មកជំនួសចៅក្រមដើម្បីគ្រប់គ្រងពួកគេ។ ព្រះបានបង្ហាញសាំយូអែលនូវបុរសម្នាក់ឈ្មោះសូល។ សូលបានក្លាយជាស្ដេចទីមួយនៃអ៊ីស្រាអែល។ ទោះបីស្ដេចសូលបានឈ្នះសង្គ្រាមជាច្រើន នៅស្រុកអ៊ីស្រាអែលក៏ដោយ តែសូលមិនមែនជាស្ដេចល្អទេ។ ទ្រង់មិនបានគោរពតាមព្រះទេ។ ស្ដេចសូលបានធ្វើអ្វីដែលព្រះបានមានបន្ទូលមក តែពេលខ្លះស្ដេចសូលបានប្រព្រឹត្តតាមបំណងព្រះហរទ័យខ្លួនឯង។ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកសាំយូអែលថា៖ «យើងសោកស្ដាយដែលយើងបានតែងតាំងសូល ជាស្ដេចអ៊ីស្រាអែល។ ទ្រង់បានបែរខ្នងមិនដើរតាមអញ ហើយមិនប្រតិបត្តិតាមបទបញ្ជារបស់អញឡើយ។

សាំយូអែលបានប្រាប់សារនោះដល់សូល។ ព្រះអម្ចាស់បានបោះបង់ចោលអ្នក មិនឲ្យធ្វើជាស្ដេចលើជនជាតិអ៊ីស្រាអែលទេ។ ព្រះអម្ចាស់បានដកហូតរាជាណាចក្រអ៊ីស្រាអែលពីលោក ហើយព្រះអង្គនឹងប្រគល់រាជ្យនេះឲ្យអ្នកដទៃទៀត»។ សាំយូអែលមិនដែលបានឃើញសូលទៀតទេ។ ព្រះទ្រង់បានមានបន្ទូលមកសាំយូអែល ឲ្យទៅជួបបុរសម្នាក់ឈ្មោះអ៊ីសាយ ដែលមកពីភូមិបេថ្លេហិម។ ព្រះបានមានបន្ទូលថា៖ «អញបានរើសកូនប្រុសម្នាក់របស់គាត់ឲ្យ ធ្វើជាស្ដេចបន្ទាប់»។ សាំយូអែលត្រូវយកសត្វទៅធ្វើយញ្ញបូជា ហើយព្រះបានបង្គាប់គាត់ឲ្យអញ្ជើញអ៊ីសាយឲ្យមកចូលរួមដែរ។ «យើងនឹងបង្ហាញអ្នកពីកូនប្រុសរបស់គាត់ ដែលយើងបានជ្រើសរើស»។ សាំយូអែលបានធ្វើដូចអ្វីដែលព្រះបានបង្គាប់មកគាត់។ គាត់បានទៅបេថ្លេហិម ហើយសុំឲ្យមេដឹកនាំក្រុងមកជាមួយគាត់ ពេលគាត់ធ្វើយញ្ញបូជា។ គាត់បានសុំឱ្យអ៊ីសាយ និងកូនប្រុសរបស់គាត់ទៅនៅទីនោះផងដែរ។ អ៊ីសាយមានកូនប្រុសប្រាំបីនាក់។ នៅពេលពួកគេមកដល់ សាំយូអែលក្រឡេកមើលកូនប្រុសឈ្មោះអេលាប។ «ប្រាកដណាស់បុរសនេះហើយ ដែលព្រះអម្ចាស់បានជ្រើសរើស!» សាំយូអែលមានប្រសាសន៍ ។

ព្រះអម្ចាស់មានព្រះបន្ទូលតបថា៖ «កុំគិតថាដោយព្រោះគេមានរាងខ្ពស់ហើយសង្ហាទើបទ្រង់ជ្រើសរើសម្នាក់នេះឲ្យសោះ។ ព្រះអម្ចាស់ មិនទតមើលអ្វីដូចអ្នកទេ។មនុស្សមើលទៅរូបរាងខាងក្រៅ។តែព្រះជាម្ចាស់ទតមើលបេះដូងរបស់មនុស្ស។ បន្ទាប់មកកូនប្រុសរបស់អ៊ីសាយបានមកដល់ គឺអ័ប៊ីណាដាប់។ លោកសាំយូអែលមានប្រសាសន៍ថា៖ «មិនមែននេះទេ!»។ បន្ទាប់មកកូនប្រុសឈ្មោះស៊ីម៉ា។ សាំយូអែលមានប្រសាសន៍ថា «ក៏មិនមែនជាម្នាក់នេះដែរ»។ កូនប្រុសបួននាក់ទៀតបានមកជួបសាំយូអែល។ ប៉ុន្តែគ្មាននរណាម្នាក់ក្នុងចំណោមពួកគេ ដែលព្រះបានជ្រើសរើសឡើយ។ «តើអ្នកទាំងអស់នេះគឺជាកូនប្រុសដែលអ្នកមានឬ?» សាំយូអែលបានសួរ អ៊ីសាយឆ្លើយថា៖ «នៅមានកូនប្រុសពៅរបស់ខ្ញុំម្នាក់ទៀត។ តែគាត់នៅឯវាលកំពុងមើលសត្វ។ សាំយូអែលមានប្រសាសន៍ថា៖ «ចូរចាត់គេឲ្យហៅគាត់មកភ្លាម!

អ៊ីសាយបាននាំយកកូនប្រុសពៅរបស់គាត់ គឺដាវីឌ។ ដាវីឌមានភ្នែកភ្លឺថ្លាមានសុខភាពល្អ និងមានរូបរាងស្អាត។ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកសាំយូអែល។ «គឺម្នាក់នេះហើយ»។ សូមទ្រង់ប្រទានពរដល់គាត់ហើយលាបប្រេងលើក្បាលរបស់គាត់។ សាំយូអែលបានស្ដាប់បង្គាប់ព្រះអម្ចាស់។ ភ្លាមៗនោះព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានមកសណ្ឋិតលើដាវីឌ ដែលមានន័យថាអំណាចចេស្ដារបស់ព្រះគឺនៅជាមួយគាត់។ ព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានចាកចេញពីស្ដេចសូល។ ស្ដេចថ្មីគឺដាវីឌដែលត្រូវបានជ្រើសរើស។ ប៉ុន្តែមួយរយៈក្រោយមកជនជាតិអ៊ីស្រាអែល បានចាត់ទុកដាវីឌជាស្ដេច ។ ព្រះមានការងារឲ្យគាត់ធ្វើជាដំបូង ។

**(១ សាំយូអែលទី ១៥, ១៦)**

## 4.04 ស្តេចមួយអង្គផ្សេងទៀតត្រូវបានជ្រើសរើស

## សេចក្តីណែនាំសម្រាប់គ្រូបង្រៀន

## កំណត់សំគាល់

១) ស្តេចសូលត្រូវបានជ្រើសរើសជាស្តេចទីមួយនៃអ៊ីស្រាអែល។ ទ្រង់មិនមែនជាស្តេចដែលស្តាប់បង្គាប់ព្រះជាម្ចាស់ទេ។ ព្រះបានមានបន្ទូលទៅសាំយូអែលថា ទ្រង់មានការសោកស្តាយដែលបានតែងតាំងសូលជាស្តេច។

២) ព្រះបានមានបន្ទូលទៅសាំយូអែល ឲ្យទៅជួបបុរសម្នាក់ឈ្មោះអ៊ីសាយ ដែលមកពីភូមិបេថ្លេហិម ។ អ៊ីសាយមានកូនប្រុសប្រាំបីនាក់ ។ ព្រះនឹងបង្គាប់ដល់សាំយូអែលថា តើមួយណាត្រូវជ្រើសរើសជាស្តេចបន្ទាប់ ។

៣) សាំយូអែលបានយកសត្វមួយក្បាលទៅធ្វើជាយញ្ញបូជា។ គាត់បានអញ្ជើញអ៊ីសាយ និងកូនប្រុសរបស់គាត់ ព្រមទាំងមេដឹកនាំនៃទីក្រុងឱ្យមកជាមួយគាត់ នៅពេលដែលគាត់ធ្វើពិធីនោះផងដែរ ។

៤) សាំយូអែលបានមើលទៅកូនប្រុស ទាំងប្រាំពីររបស់អ៊ីសាយ។ ប៉ុន្តែព្រះបានប្រាប់សាំយូអែលថា គ្មានកូនប្រុសណាម្នាក់ ដែលព្រះបានជ្រើសរើសទេ។ អ៊ីសាយបាននិយាយថា ខ្ញុំមានកូនប្រុសម្នាក់ទៀត នៅឯវាលមើលសត្វ។ កូនប្រុសនេះឈ្មោះដាវីឌ។ នៅពេលដាវីឌមកដល់ព្រះ ទ្រង់បានមានបន្ទូលទៅសាំយូអែលថា នេះជាបុរសដែលទ្រង់បានជ្រើសរើសឲ្យធ្វើជាស្តេច។

៥) សាំយូអែលចាក់ប្រេងជាសញ្ញា នៃព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះនៅលើក្បាលដាវីឌ ដូចព្រះអម្ចាស់បានបង្គាប់គាត់ឲ្យធ្វើដូច្នេះ។ បន្ទាប់មកព្រះវិញ្ញាណបរិសុទ្ធ បានយាងមកសណ្ឋិតលើដាវីឌ ដែលមានន័យថា អំណាចចេស្តារបស់ព្រះ គឺគង់នៅជាមួយគាត់។ ពេលព្រះវិញ្ញាណបរិសុទ្ធយាងមកសណ្ឋិតលើដាវីឌ ព្រះវិញ្ញាណបរិសុទ្ធក៏ចាកចេញពីស្តេចសូលទៅ ។

### សំណួរ

១) ហេតុអ្វីបានជាព្រះចង់ជ្រើសរើស ស្តេចមួយផ្សេងទៀត?

២) តើព្រះបានបង្គាប់សាំយូអែលឲ្យរកអ្នកណា?

៣) តើអ៊ីសាយមានកូនប្រុសប៉ុន្មាននាក់?

៤) តើកូនប្រុសមួយណា ដែលកំពុងធ្វើការនៅឯស្រែ?

៥) តើព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើដាវីឌ មានន័យយ៉ាងណា?

### ចម្លើយ

១) ព្រះអម្ចាស់ចង់បានស្តេចមួយទៀត ពីព្រោះស្តេចសូលមិនបានស្តាប់បង្គាប់ទ្រង់ទេ។

២) ព្រះបានបង្គាប់សាំយូអែល ឲ្យរកបុរសម្នាក់ឈ្មោះអ៊ីសាយ។

៣) អ៊ីសាយមានកូនប្រុស ៨នាក់។

៤) ដាវីឌដែលជាកូនប្រុសរបស់អ៊ីសាយ កំពុងធ្វើការនៅវាលស្រែ។

៥)នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធ បានយាងមកសណ្ឋិតលើដាវីឌវាមានន័យថា អំណាចចេស្តារបស់ព្រះគឺគង់នៅជាមួយគាត់។


Kids of Destiny
Reaching the Next Generation
www.kidsofdestiny.org